**វិទ្យាស្ថានសភាកម្ពុជា**

**PARLIAMENTARY INSTITUTE OF CAMBODIA**

STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ០៧ ខែ ធ្នូ ២០១៨**

---

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ធនាគារពិភពលោកចេញផ្សាយឯកសារទស្សនវិស័យសម្រាប់ប្រទេសកម្ពុជា ដោយផ្តល់យោបល់ឱ្យមានការប្រុងប្រយ័ត្នចំពោះគោលដៅប្រាក់ចំណូល
- ប្រទេសប៉ាណាម៉ា និងប្រទេសចិន ចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួនដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរកាន់តែខិតជិតគ្នា
- សហរដ្ឋអាមេរិក និងប្រទេសចិន ឯកភាពគ្នាបញ្ឈប់សង្គ្រាមពាណិជ្ជកម្ម

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ធនាគារពិភពលោកចេញផ្សាយឯកសារទស្សនវិស័យសម្រាប់ប្រទេសកម្ពុជា ដោយផ្តល់យោបល់ឱ្យមានការប្រុងប្រយ័ត្នចំពោះគោលដៅប្រាក់ចំណូល

ធនាគារពិភពលោកបានចេញផ្សាយជាសាធារណៈអំពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាក្នុងសប្តាហ៍នេះ(pdf)។ ខ្លឹមសារនៃរបាយការណ៍គឺការសម្រេចបាននូវគោលដៅចំណូលរបស់កម្ពុជា។ របាយការណ៍នេះបានសន្និដ្ឋានថា រដ្ឋាភិបាលមានសុទិដ្ឋិនិយមពេកនៅក្នុងគោលដៅសម្រេចអោយបានជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ ហើយបើគិតអត្រាកំណើនបច្ចុប្បន្ន និងតាមការព្យាករណ៍ទៅពេលអនាគត គោលដៅគួរតែត្រូវបានធ្វើការកែសម្រួលទៅដល់ឆ្នាំ២០៣៥វិញ។ គោលដៅឆ្នាំ២០៣០អាចសម្រេចបាន លុះត្រាតែកំណើនផ.ស.ស.សម្រាប់មនុស្សម្នាក់ៗមានចំនួន៩,៣% ក្នុងរយៈពេល១៣ឆ្នាំខាងមុខ ខណៈពេលបច្ចុប្បន្ន វាមានត្រឹមចន្លោះពី៥% ទៅ៦%។ ការសម្រេចបានក្នុងឆ្នាំ២០៣៥ ហាក់មានភាពប្រាកដប្រជាជាង បើធៀបជាមួយនឹងបទពិសោធន៍មុនៗនៃបណ្តាប្រទេសដែលជាខ្លាក្នុងតំបន់អាស៊ី។

ធនាគារពិភពលោកបានព្យាករណ៍ថា កម្ពុជានឹងមានកំណើន៧,១%ក្នុងឆ្នាំនេះ ដែលខ្ពស់ជាងឆ្នាំ២០១៧ និងខ្ពស់ជាងការរំពឹងទុក។ ទោះជាយ៉ាងណាក៏ដោយ ក្រុមអ្នកវិភាគរបស់ធនាគារពិភពលោករំពឹងទុកថា កំណើននឹងថមថយនៅត្រឹម៦,៨%ក្នុងអំឡុងពេល២ឆ្នាំខាងមុខ ដោយសារការរីកចំរើនផ្នែកសារពើពន្ធនឹងថយចុះ ហើយសេដ្ឋកិច្ចនឹងត្រលប់ទៅរកសក្តានុពលរយៈពេលវែងវិញ។

## តារាងប្រចាំសប្តាហ៍៖ ចំណូលពន្ធប្រចាំខែ

របាយការណ៍ប្រចាំសប្តាហ៍នេះបង្ហាញពីចំណូលពន្ធប្រចាំខែរបស់កម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ២០១៧ ដល់ខែសីហាឆ្នាំ ២០១៨។ ចំណូលពន្ធក្នុងខែសីហាបានកើនឡើងដល់ ៣៦១,៧លានដុល្លារ គឺកើនឡើងពី២៩៥,៦លានដុល្លារកាលពីខែមុន។ ប្រាក់ចំណូលបានឈានដល់កម្រិតខ្ពស់បំផុតគឺ៤១៣,៦លានដុល្លារនៅក្នុងខែមីនាឆ្នាំ២០១៨ និងប្រាក់ចំណូលទាបបំផុតគឺ២៣៧,៤លានដុល្លារនៅក្នុងខែវិច្ឆិកាឆ្នាំ២០១៧។ ចំណូលពន្ធប្រចាំខែជាមធ្យមគឺ៣១៦,៧លានដុល្លារ។

**ចំណូលពន្ធប្រចាំខែរបស់ប្រទេសកម្ពុជា ពីខែកញ្ញាឆ្នាំ ២០១៧ ដល់ខែសីហាឆ្នាំ ២០១៨ (គិតជាលានដុល្លារ)**




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រទេសប៉ាណាម៉ា និងប្រទេសចិន ចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួន ដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរកាន់តែខិតជិតគ្នា

នៅសប្តាហ៍នេះប្រទេសប៉ាណាម៉ា និងចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួន១៩ ដើម្បីភ្ជាប់សេដ្ឋកិច្ចរបស់ខ្លួនឲ្យកាន់តែខិតជិតគ្នា។ កិច្ចព្រមព្រៀងទាំងនោះផ្តោតលើវិស័យពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ ធនាគារ និងទេសចរណ៍។ ប្រទេសទាំងពីរបានចុះហត្ថលេខានៅអំឡុងទស្សនកិច្ចលើកដំបូងរបស់ប្រធានាធិបតី ស៊ីជីនពីង ទៅកាន់ប្រទេសប៉ាណាម៉ា បន្ទាប់ពីប្រទេសទាំងពីរបានបើកឲ្យមានទំនាក់ទំនងការទូតកាលពីឆ្នាំមុន។ កិច្ចព្រមព្រៀងនោះ ក៏រួមបញ្ចូលលក្ខខណ្ឌដែលប្រទេសចិននឹងផ្តល់ជំនួយឥតសំណងដល់ប្រទេសប៉ាណាម៉ា ទោះបីជាចំនួនទឹកប្រាក់នោះមិនត្រូវបានបង្ហាញក៏ដោយ។ កិច្ចព្រមព្រៀងនោះ បានកត់សម្គាល់ឲ្យឃើញនូវការផ្លាស់ប្តូរគួរឲ្យចាប់អារម្មណ៍ ដោយប្រទេសចិនចូលទៅក្នុងតំបន់មួយដែលត្រូវបានគាំទ្រដោយសហរដ្ឋអាមេរិក។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### សហរដ្ឋអាមេរិក និងប្រទេសចិន ឯកភាពគ្នាបញ្ឈប់សង្គ្រាមពាណិជ្ជកម្ម

កាលពីថ្ងៃសៅរ៍កន្លងទៅនេះ អាមេរិក និងចិន បានប្រកាសបញ្ឈប់សង្គ្រាមពន្ធគយរបស់ពួកគេ បន្ទាប់ពីកិច្ចប្រជុំក្រៅផ្លូវការមួយនៅឯកិច្ចប្រជុំកំពូលG20 នៅទីក្រុងBuenos Aires ប្រទេសអាហ្សង់ទីន។ ប្រធានាធិបតី Trump បានពន្យារពេលការគម្រាមកំហែងដែលគ្រោងលើការបង្កើនពន្ធពី១០%ដល់២៥% នៅថ្ងៃទី០១ខែមករាខាងមុខនេះ ដោយយល់ព្រមផ្តល់រយៈពេល៩០ថ្ងៃសម្រាប់ការចរចាដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងប្រទេសទាំងពីរ។

ប្រធានបទសម្រាប់ចរចា រួមមាន របាំងពាណិជ្ជកម្ម និងជម្លោះកម្មសិទ្ធិបញ្ញា។ លោក Wang Yi រដ្ឋមន្ត្រីការបរទេសចិន បានប្រាប់អ្នកយកព័ត៌មានក្នុងទីក្រុងBuenos Aires អោយដឹងថា កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរមានសារៈសំខាន់សម្រាប់សុខុមាលភាពរបស់ប្រជាជនចិន និងអាមេរិក ហើយនិងចំពោះកំណើនសេដ្ឋកិច្ច និងស្ថេរភាពសេដ្ឋកិច្ចពិភពលោក។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខ រួមមាន៖ ផ.ស.ស.នៅប្រទេសជប៉ុន និងការប្រកាសអត្រាការប្រាក់នៅក្នុងប្រទេសហ្វីលីពីន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី១០ ខែធ្នូ

- ផ.ស.ស.របស់ជប៉ុន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨ តាមការប៉ាន់ប្រមាណចុងក្រោយ

- គណនីចរន្តរបស់ជប៉ុន សម្រាប់ខែតុលា
- ការលក់រាយរបស់ឥណ្ឌូនេស៊ី សម្រាប់ខែតុលា
- ការវិនិយោគផ្ទាល់ពីបរទេសរបស់ហ្វីលីពីន សម្រាប់ខែកញ្ញា

ថ្ងៃអង្គារ ទី១១ ខែធ្នូ

- តុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីន សម្រាប់ខែតុលា
- ការលក់រថយន្តរបស់ចិន សម្រាប់ខែវិច្ឆិកា
- ការបញ្ជាទិញម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែវិច្ឆិកា

ថ្ងៃពុធ ទី១២ ខែធ្នូ

- អត្រាភាពគ្មានការងារធ្វើរបស់កូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍ថ្លៃផលិតរបស់ជប៉ុន សម្រាប់ខែវិច្ឆិកា
- ផលិតកម្មឧស្សាហកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែតុលា
- ការលក់រាយនៅសិង្ហបុរី សម្រាប់ខែតុលា
- ការវិយោគផ្ទាល់ពីបរទេសរបស់ចិន សម្រាប់ខែវិច្ឆិកា

ថ្ងៃព្រហស្បត្តិ៍ ទី១៣ ខែធ្នូ

- តម្លៃនាំចេញ នាំចូលរបស់កូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- ការវិនិយោគមូលបត្របរទេសរបស់ជប៉ុន សម្រាប់ថ្ងៃទី០៨ ខែធ្នូ
- អត្រាភាពគ្មានការងារធ្វើនៅសិង្ហបុរី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ការលក់រាយនៅម៉ាឡេស៊ី សម្រាប់ខែតុលា
- ការសម្រេចចិត្តអត្រាការប្រាក់របស់ហ្វីលីពីន

ថ្ងៃសុក្រ ទី១៤ ខែធ្នូ

- ការលក់រាយរបស់ចិន សម្រាប់ខែវិច្ឆិកា
- ការលក់ម៉ូតូនិងឡានរបស់ឥណ្ឌូនេស៊ី សម្រាប់ខែវិច្ឆិកា
- អត្រាភាពគ្មានការងារធ្វើរបស់ម៉ាឡេស៊ី សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មជប៉ុន សម្រាប់ខែតុលា
- ផលិតកម្មឧស្សាហកម្មហុងកុង សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨